# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ២៩៩ ព្រទ.កយ/០៣

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
### សូមជម្រាបមក

**លោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង**

**លោកព្រះរាជអាជ្ញាគ្រប់អយ្យការខេត្ត-ក្រុង**

**កម្មវត្ថុ:** អំពីការសុំកូនយកទៅចិញ្ចឹមរបស់ជនបរទេស តាមរយៈតុលាការ ។

**យោង:** លិខិតលេខ ៣៣៦ កបទ.សអ.ច្បក២ ចុះថ្ងៃទី២០/០១/២០០៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

ខ្ញុំសូមជម្រាបអស់លោកថា កន្លងមកមានការជួញដូរកុមារតាមរយៈការសុំកូនយកទៅចិញ្ចឹមដោយជនបរទេស ។ ដើម្បីទប់ស្កាត់ការជួញដូរនេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ២៩អនក្រ.បក ចុះថ្ងៃទី១៤/០៣/២០០១ ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស ។

បច្ចុប្បន្ននេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានសង្កេតឃើញថាមានជនបរទេសជាច្រើនបានគេចវេសពីនីតិវិធីនៃការសុំកូនតាមអនុក្រឹត្យខាងលើ ហើយទៅឃុបឃិតសុំកូន ឬទិញកុមារពីឪពុកម្តាយក្រីក្ររួចទៅសុំតុលាការកាត់សេចក្តីសម្រេច ។ រូបភាពនេះជាការបង្កលក្ខណៈងាយស្រួលមួយដល់ការជួញដូរកុមារកម្ពុជាយើងដែលយើងត្រូវតែរួមគ្នាទប់ស្កាត់ ។

តាមមាត្រា១១៣ វាក្យខណ្ឌទី១ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ការសុំកូនតាមរយៈតុលាការអាចអនុវត្តបានតែក្នុងប្រទេសប៉ុណ្ណោះ ។ ចំពោះការសុំកូនដោយជនបរទេសយកទៅចិញ្ចឹមនៅបរទេស ដែលមិនមានច្បាប់ចែងច្បាស់លាស់ត្រូវតែអនុវត្តតាមនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យខាងលើប្រយោជន៍ងាយស្រួលឱ្យរាជរដ្ឋាភិបាលក្តាប់បានអំពីចំនួនទារក និងកុមារដែលត្រូវសុំយកទៅចិញ្ចឹមជាកូននៅបរទេស ហើយអាចមានលទ្ធភាពតាមដានអំពីសកម្មភាពចិញ្ចឹមរបស់ពួកគេ រហូតដល់ទារក និងកុមារទាំងនោះក្លាយជានីតិជន ។

ដូច្នេះចាប់ពីពេលនេះតទៅ គ្រប់តុលាការខេត្ត-ក្រុង ត្រូវជៀសវាងការចេញសាលក្រមសម្រេចសេចក្តីប្រគល់ទារក ឬកុមារឱ្យទៅជនបរទេសដែលជាអំពើខុសឆ្គងមួយពីព្រោះច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារមិនមានកំណត់ចែងអំពីប្រការនេះឡើយ ហើយបើមានភាគីណាប្តឹងសុំពីរឿងនេះសូមអស់លោកជួយពន្យល់អោយគេអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ ។

ទទួលបានសេចក្តីណែនាំនេះ សូមអស់លោកយកស្មារតីទទួលខុសត្រូវខ្ពស់អនុវត្តឱ្យមានប្រសិទ្ធភាព ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣

**រដ្ឋមន្ត្រី**

**នាង ស៊ីផុន**

ចម្លងជូន
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-តុលាការកំពូល
-មហាអយ្យការតុលាការកំពូល
-សាលាឧទ្ធរណ៍
-មហាអយ្យការអមសាលាឧទ្ធរណ៍
" ដើម្បីជ្រាប " ។